ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦០.សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង បង្ក្រាបបទល្មើស ភាពយន្ត និង វីដេអូ ក្នុងព្រះរាជាណាចក្រកម្ពុជា

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រិត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

-បានឃើញអនុក្រិត្យលេខ ៦២ អនក្រ. បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

-បានឃើញអនុក្រិត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យ សិល្បៈភាពយន្ត និង វីដេអូ

-តាមសំណើរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

## សំ រេ ច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីត្រួតពិនិត្យ និង ចាត់វិធានការបង្ក្រាប ការបញ្ចាំងវីដេអូអាសអាភាស ការលក់ ឬ ជួល ស្នាដៃភាពយន្ត និង ស្នាដៃវីដេអូអាសអាភាស គ្មានទិដ្ឋាការគ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាព ដូចខាងក្រោម :

១-លោក ឃឹម សារិទ្ធ អគ្គនាយករងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាប្រធាន

២-លោក សៅ ប៊ុនធឿន អនុប្រធាននាយកដ្ឋានព័ត៌មានទូទៅក្រសួងមហាផ្ទៃ ជាអនុប្រធាន

៣-លោក គង់ កន្ថាក់ អនុប្រធាននាយកដ្ឋានសិល្បៈភាពយន្តនិងផ្សព្វផ្សាយវប្បធម៌ ជាសមាជិកអចិន្ត្រៃយ៍

៤-លោក ហង់ ជូនណារិទ្ធ អនុប្រធានការិយាល័យនៃនាយកដ្ឋានព័ត៌មានទូទៅនៃក្រសួងមហាផ្ទៃ ជាសមាជិក

៥-លោកវរៈសេនីយ៍ត្រី សិរិទ្ធ ឈុន នាយកដ្ឋានឃោសនាសាធារណៈក្រសួងការពារជាតិ ជាសមាជិក

៦-លោកវរៈសេនីយ៍ត្រី រាជ សុខហេង នាយកដ្ឋានអធិការកិច្ចទូទៅ ក្រសួងការពារជាតិ ជាសមាជិក

៧-លោក ប៊ូ ប៊ុនហ៊ាង មន្ត្រីច្បាប់ ក្រសួងយុត្តិធម៌ ជាសមាជិក

៨-លោក ខឹម សោភ័ណ ប្រធាននាយកដ្ឋានក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ជាសមាជិក

៩-លោកស្រី សាត សាលីម អនុប្រធាននាយកដ្ឋានក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ជាសមាជិក

១០-លោក កែន សុភី មន្ត្រី ក្រសួងទេសចរណ៍ ជាសមាជិក

១១-លោក យូន សុភាព មន្ត្រី ក្រសួងទេសចរណ៍ ជាសមាជិក

១២-លោក គីម សារិន មន្ត្រី ក្រសួងព័ត៌មាន ជាសមាជិក

១៣-លោក ឈ ឈុនសៀ មន្ត្រី ក្រសួងព័ត៌មាន ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ច :

- តាមដាន និង ពិនិត្យការអនុវត្តន៍អនុក្រឹត្យ លេខ ៦៣ អនក្រ បក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត និង វីដេអូ ។
- សហការជាមួយគណៈកម្មការចំរុះ និងអាជ្ញាធរដែនដី គ្រប់ខេត្ត-ក្រុង ក្នុងការអនុវត្តន៍អនុក្រឹត្យ សារាចរ និង លិខិតបទដ្ឋានផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យ ភាពយន្ត វីដេអូ ។
- តាមដានត្រួតពិនិត្យ ដើម្បីកែលំអរ ពង្រឹង និង ពង្រីកការងារទប់ស្កាត់បង្ក្រាប ព្រមទាំងបំបាត់ការធ្វើអាជីវកម្ម សេវាកម្ម ភាពយន្ត វីដេអូ ខារ៉ាអូខេ អនាធិបតេយ្យទូទាំងប្រទេស ។
- ចូលពិនិត្យរោងបញ្ចាំងភាពយន្ត រោងបញ្ចាំងវីដេអូ កន្លែងធ្វើអាជីវកម្មខារ៉ាអូខេ តាមស្ថានីយ៍ទូរទស្សន៍ និង ទូរទស្សន៍ខ្សែកាបទូទាំងប្រទេស ក្នុងការចាក់បញ្ចាំងផលិតផល ភាពយន្ត វីដេអូ គ្រប់ប្រភេទ ។
- ត្រួតពិនិត្យកន្លែងធ្វើអាជីវកម្ម ជួល លក់ ខ្សែភាពយន្ត កាសែ្សតវីដេអូ ឡាស៊ែរឌីស ស៊ីឌីវីដេអូ ឌីវីឌី គ្រប់ប្រភេទ លើការដាក់តាំងជួល លក់ នៅតាមទីផ្សារ ក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ធ្វើកំណត់ហេតុ រៀបចំសំណុំរឿងពាក់ព័ន្ធបទល្មើស និង រាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

ប្រការ ៣ : សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រការ ៤ ៖ គណៈកម្មការអន្តរក្រសួង បង្ក្រាបបទល្មើស ភាពយន្ត និង វីដេអូ មានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

ប្រការ ៥ ៖ សេចក្តីសំរេច លេខ ១៤ សសរ. ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មការអន្តរ-ក្រសួង បង្ក្រាបការធ្វើអាជីវកម្ម បញ្ចាំង និង លក់ កាសែត្រវីដេអូអាសអាភាស ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអស់លោក លោកស្រី ដូចមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល ៖

-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៦
-គ្រប់ខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ